ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងអនុវត្ត

# មុខងារការពង្រឹងការងារអប់រំបរិស្ថាន

រវាង

អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន នៃក្រសួងបរិស្ថាន

និង

រដ្ឋបាលខេត្តបាត់ដំបង

ចាប់ពីខែមករា ឆ្នាំ២០១៦ ដល់ខែធ្នូ ឆ្នាំ២០១៨

ក្រសួងបរិស្ថាន តំណាងដោយអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ហៅថា (ក្រសួង) និងរដ្ឋបាលខេត្ត តំណាងដោយអភិបាលខេត្ត ហៅថា (រដ្ឋបាលខេត្ត)។ ស្ថាប័នទាំងពីរនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានហៅថា(ភាគី)ដែលបានចុះហត្ថលេខាក្នុងកិច្ចព្រមព្រៀងនេះពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ សំដៅធានាឱ្យមានប្រសិទ្ធភាពសម្រាប់ការផ្ទេរ មុខងារការពង្រឹងការងារអប់រំបរិស្ថាន ខេត្តបាត់ដំបង។ កិច្ចព្រមព្រៀងរវាងរដ្ឋបាលខេត្ត និងក្រសួងបរិស្ថាននឹងផ្តល់ការណែនាំចំពោះខេត្ត នូវលក្ខណៈវិនិច្ឆ័យនៃការអនុវត្ត ការកំណត់អំពីតួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ និងបង្កើតយន្តការ សម្រាប់ការរាយការណ៍ និងតាមដានត្រួតពិនិត្យ ក្នុងការអនុវត្តសាកល្បង មុខងារការពង្រឹងការងារអប់រំបរិស្ថាន ខេត្តបាត់ដំបងនេះ។

## ១-គោលការណ៍ទូទៅ

មុខងារការពង្រឹងការងារអប់រំបរិស្ថាន រួមមាន៖

- លើកកំពស់ការយល់ដឹងបរិស្ថានតាមរយៈការរៀបចំសាលាមេត្រីបរិស្ថាន (Eco School) នៅតាមសាលារៀនទាំងថ្នាក់បឋម និងមធ្យមសិក្សា
- លើកកំពស់ការយល់ដឹងបរិស្ថានតាមរយៈការកសាងសមត្ថភាព បើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការធ្វើបទបង្ហាញផ្សេងៗ
- លើកកំពស់ការយល់ដឹងបរិស្ថានតាមរយៈការកសាងទំនាក់ទំនង និងបង្កើនកិច្ចសហការ ជាមួយស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល ដើម្បីរៀបចំព្រឹត្តិការណ៍បរិស្ថាននានា

កិច្ចព្រមព្រៀងនេះ មានសុពលភាពចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ នឹងមានវិសាលភាពសម្រាប់តែការអនុវត្តមុខងារ ការពង្រឹងការងារអប់រំបរិស្ថាន ខេត្តបាត់ដំបង។ រាល់ការកែប្រែកិច្ចព្រមព្រៀងនេះ គឺត្រូវធ្វើឡើងលើមូលដ្ឋាននៃការអនុវត្តការពង្រឹងការងារអប់រំបរិស្ថាន នៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខេត្ត ដូចមានចែងក្នុងប្រកាសលេខ.............. ចុះថ្ងៃទី........... ខែ.......ឆ្នាំ២០១៥ របស់ក្រសួងបរិស្ថាន ស្តីពីការធ្វើប្រតិភូកម្មមុខងារការពង្រឹងការងារអប់រំបរិស្ថាន ខេត្តបាត់ដំបង។

## ២-ការអនុវត្តការពង្រឹងការងារអប់រំបរិស្ថាន ដោយរដ្ឋបាលបាត់ដំបង

កម្មវត្ថុ នៃកិច្ចព្រមព្រៀងនេះបង្កើតឡើង សម្រាប់អនុវត្តន៍មុខងារការពង្រឹងការងារអប់រំបរិស្ថាន ដោយខេត្ត ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ សេវាទាំងនេះត្រូវតែផ្តល់ដោយខេត្ត ដែលបានកំណត់ នៅក្នុងកិច្ចព្រមព្រៀងនេះ។

នៅពេលកាលបរិច្ឆេទ ផ្ទេរមុខងារការពង្រឹងការងារអប់រំបរិស្ថាន ទៅឱ្យខេត្តបាត់ដំបង ចូលជាធរមាន រដ្ឋបាលខេត្តនឹងត្រូវទទួលខុសត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- ចលនា និងរៀបចំសាលាមេត្រីបរិស្ថាន នៅតាមសាលារៀន ទាំងថ្នាក់បឋម និងថ្នាក់មធ្យមសិក្សា
- រៀបចំវគ្គបណ្តុះបណ្តាលអប់រំបរិស្ថានដល់មន្ត្រីមន្ទីរពាក់ព័ន្ធ និងដល់មន្ត្រីក្រុមប្រឹក្សាឃុំសង្កាត់
- សហការជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដើម្បីរៀបចំព្រឹត្តការណ៍បរិស្ថានជាតិ និងអន្តរជាតិនានា
- ធ្វើការជាមួយអ្នកសារព័ត៌មាន ដើម្បីផ្សព្វផ្សាយការយល់ដឹងដល់សាធារណជនអំពីបរិស្ថាន
- ពិនិត្យ តាមដាន វាយតម្លៃលទ្ធផលសកម្មភាព និងលើកទឹកចិត្តដល់សាលារៀនថ្នាក់បឋម និងមធ្យមសិក្សា ក្នុងការជំរុញការងារអប់រំបរិស្ថាន
- ធ្វើរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តមុខងារប្រតិភូកម្មនេះ ប្រចាំខែប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនក្រសួងបរិស្ថាន ។

រដ្ឋបាលខេត្ត ត្រូវសម្រេចយកការិយាល័យណាមួយ នៃរដ្ឋបាលខេត្តរបស់ខ្លួនឱ្យទទួលខុសត្រូវសម្របសម្រួល មុខងារដែលបានផ្ទេរនេះ។ នៅក្នុងការទទួលអនុវត្តមុខងាររបស់ខ្លួននេះ រដ្ឋបាលខេត្តត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ៣.តួនាទីនៃភាគីនីមួយៗ

នៅពេលកាលបរិច្ឆេទផ្ទេរមុខងារចូលជាធរមាន តួនាទីភាគីពាក់ព័ន្ធក្នុងការអនុវត្តមុខងារ ការពង្រឹងការងារអប់រំបរិស្ថាន មានដូចខាងក្រោម៖

៣.១-ក្រសួងបរិស្ថានផ្តល់នូវថវិកាប្រចាំឆ្នាំរបស់ខ្លួន ហើយបែងចែកថវិកាទៅឱ្យរដ្ឋបាលខេត្ត ដូចដែលកំណត់នៅក្នុងផ្នែកទី៥ នៃកិច្ចព្រមព្រៀងនេះ។ រដ្ឋបាលខេត្ត ត្រូវទទួលខុសត្រូវ ក្នុងការគ្រប់គ្រងចាត់ចែងថវិកាដែលបានផ្តល់ឱ្យនេះ។ ក្រសួងនឹងផ្តល់ការគាំទ្រផ្នែករដ្ឋបាល និងការគាំទ្រដទៃ ដូចជាកិច្ចសហការជាមួយភ្នាក់ងាររដ្ឋាភិបាលនៅគ្រប់ថ្នាក់ និងផ្តល់នូវការគាំទ្រចាំបាច់ផ្សេងៗទៀត តម្រូវការឯកសារលិខិតបទដ្ឋានទូទៅ លិខិតបទដ្ឋានពិសេស និងបច្ចេកទេស។

៣.២-ក្រសួងបរិស្ថាន តាមរយៈមន្ទីរបរិស្ថានខេត្ត ផ្តល់នូវការណែនាំអភិវឌ្ឍន៍សមត្ថភាព តាមរយៈការបណ្តុះបណ្តាល និងជួយជំរុញរដ្ឋបាលខេត្ត ក្នុងការអនុវត្ត ដោយផ្អែកតាមរបាយការណ៍

ដែលខ្លួនបានទទួល និងផ្តល់នូវការត្រួតពិនិត្យមើលបច្ចេកទេស សម្រាប់ការអនុវត្តមុខងារការពង្រឹងការងារអប់រំបរិស្ថាន

៣.៣-រដ្ឋបាលខេត្ត ត្រូវជ្រើសរើសយកការិយាល័យណាមួយចំណុះឱ្យរដ្ឋបាលខេត្ត ជួយក្នុងការអនុវត្តមុខងារនេះ ។

៣.៤-ក្រសួងបរិស្ថានដោយសហការជាមួយលេខាធិការដ្ឋានគ.ជ.អ.ប ក្នុងការរៀបចំសៀវភៅណែនាំ ដើម្បីឱ្យរដ្ឋបាលខេត្ត អនុវត្តមុខងារ ដូចដែលមានចែងនៅចំណុច២ នៃកិច្ចព្រមព្រៀងឱ្យមានប្រសិទ្ធភាព។

**៤-សហប្រតិបត្តិការរវាងរដ្ឋបាលខេត្ត រដ្ឋបាលស្រុក ក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការ អភិវឌ្ឍន៍ភូមិ**

រដ្ឋបាលខេត្តត្រូវសម្របសម្រួលជាមួយក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធនានា ដើម្បីកសាងផែនការ និងកម្មវិធីវិនិយោគប្រចាំឆ្នាំ និងការតាមដានត្រួតពិនិត្យលើការអនុវត្តមុខងារការពង្រឹងការងារអប់រំបរិស្ថាន នៅក្នុងរដ្ឋបាលខេត្តរបស់ខ្លួន។

ដោយផ្អែកលើធនធានដែលមាន និងសេចក្តីត្រូវការជាក់ស្តែងនៅមូលដ្ឋាន ខេត្តជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធនានាតាមរយៈផ្តល់ការហ្វឹកហ្វឺនណែនាំ និងពង្រឹងការគ្រប់គ្រងថវិកា។

**៥ប្រភពមូលនិធិ- និងយន្តការផ្ទេរមូនិធិ**

ក្នុងឆ្នាំ២០១៦ ក្រសួងបរិស្ថានផ្តល់ទៅឱ្យរដ្ឋបាលខេត្តនូវថវិកាចំនួន............................រៀល (................................រៀលគត់) ដើម្បីអនុវត្តមុខងារដែលត្រូវបានផ្ទេរ។ នៅត្រីមាសទី៣ ឆ្នាំ២០១៦ និងនៅត្រីមាសទី៣ ឆ្នាំ២០១៧ ក្រសួងបរិស្ថាននិងជូនដំណឹងទៅ រដ្ឋបាលខេត្តអំពីការវិភាជន៍ថវិកាឆ្នាំ២០១៧ និងឆ្នាំ២០១៨ សម្រាប់ការពង្រឹងការងារអប់រំបរិស្ថាន។

រដ្ឋបាលខេត្តនឹងរួមចំណែកមូលនិធិរបស់ខ្លួន ដោយផ្អែកលើស្ថានភាពចំណូលផ្ទាល់ជាក់ស្តែង និងផ្អែកលើតម្រូវការមូលនិធិ សម្រាប់អនុវត្តមុខងារនេះ។ ការអនុវត្តថវិកាដែលបានផ្ទេរពីក្រសួងបរិស្ថាន ត្រូវអនុវត្តន៍តាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក ។

**៦ការផ្ទេរបុគ្គលិក-**

ក្រសួងបរិស្ថានរៀបចំផ្ទេរបុគ្គលិករបស់ខ្លួននៅក្នុងដំណើរការផ្ទេរមុខងារនេះ។ ជាមួយគ្នានោះដែរ ដើម្បីទទួលខុសត្រូវ ក្នុងការអនុវត្តមុខងារការពង្រឹងការងារអប់រំបរិស្ថាន នៅក្នុងរដ្ឋបាលខេត្តរបស់ខ្លួន ។ ប្រសិនបើក្រសួងបរិស្ថានមិនមានបុគ្គលិក សម្រាប់ការអនុវត្តមុខងារការពង្រឹងការងារអប់រំបរិស្ថាន នៅថ្នាក់ខេត្ត រដ្ឋបាលខេត្តត្រូវចាត់តាំងបុគ្គលិករបស់ខ្លួន ឬជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ស្របតាមនីតិវិធីជ្រើសរើស បុគ្គលិកជាប់កិច្ចសន្យាដែលមានស្រាប់ ។

## ៧-ការតាមដានត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការវាយតម្លៃ

ផ្អែកលើកម្មវិធីវិនិយោគប្រចាំឆ្នាំរបស់ខ្លួន រដ្ឋបាលខេត្តត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ ស្ដីពីការអនុវត្តមុខងារការពង្រឹងការងារអប់រំបរិស្ថាននៅក្នុងខេត្ត ដោយពណ៌នាពីស្ថានភាព និងវឌ្ឍនភាពក្នុងការពង្រឹងការងារអប់រំបរិស្ថាននៅក្នុងខេត្ត បង្ហាញពីសកម្មភាពដែលបានអនុវត្តកន្លងមក និងតម្រូវការសម្រាប់ឆ្នាំបន្ទាប់ទៀត។ នីតិវិធី និងទម្រង់នានា សម្រាប់ធ្វើរបាយការណ៍ ត្រូវបង្ហាញពីសមិទ្ធផលសម្រេច បានដោយធៀបទៅនឹងសូចនាករអនុវត្តន៍ដែលបានកំណត់ក្នុងផែនការលើកកម្ពស់ការគ្រប់គ្រង សម្រាប់ទូទាំងខេត្ត ហើយត្រូវបានណែនាំជាគំរូក្នុងសៀវភៅណែនាំ ដែលកំណត់ដោយក្រសួងបរិស្ថាន និងលេខាធិការដ្ឋាន គ.ជ.អ.ប

រដ្ឋបាលខេត្តត្រូវផ្ដល់ព័ត៌មានអំពីស្ថានភាព និងវឌ្ឍនភាពក្នុងក្នុងការអនុវត្តមុខងារនេះ តាមការស្នើសុំ របស់ក្រសួងបរិស្ថាន។

ក្រសួងបរិស្ថាននឹងត្រួតពិនិត្យមើលការអនុវត្តមុខងារ របស់រដ្ឋបាលខេត្ត ក្នុងការផ្ដល់ការពង្រឹងការងារអប់រំបរិស្ថានយ៉ាងតិច២ដងក្នុងមួយឆ្នាំដូចដែលមានរៀបរាប់ក្នុងកិច្ចព្រមព្រៀងនេះ និងធ្វើការពិនិត្យ។

មើលលទ្ធផលសម្រេចបានធៀបនឹងសូចនាករ អនុវត្តមុខងារដូចមានក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលខេត្ត។

នៅពាក់កណ្ដាលឆ្នាំ២០១៨ ក្រសួងបរិស្ថាននឹងធ្វើសេចក្ដីរបាយការណ៍ស្ដីពីលទ្ធផល ក្នុងការអនុវត្តមុខ របស់ខេត្តគោលដៅទៅគ.ជ.អ.ប។

## ៨-សុពលភាព ដំណោះស្រាយវិវាទ អវសានបញ្ញត្តិ

កិច្ចព្រមព្រៀងនេះ នឹងត្រូវអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខាដោយភាគីទាំងពីរ និងមានសុពលភាពរយៈពេល០៣(បី)ឆ្នាំ ដូចមានចែងក្នុងរបស់ក្រសួងបរិស្ថាន ចុះថ្ងៃទី........ខែ.........ឆ្នាំ២០១៥ ឬផ្អែកតាមការកែសម្រួលក្នុងប្រកាសនោះ។

ភាគីទាំងពីរនឹងខិតខំដោះស្រាយរាល់វិវាទ ដែលកើតមានក្នុងពេលអនុវត្តន៍ កិច្ចព្រមព្រៀងនេះ ដោយការពិភាក្សាគ្នា។ រាល់ការផ្លាស់ប្តូរ និងការកែសម្រួលលើខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ ត្រូវសរសេរជាលាយលក្ខណ៍អក្សរហើយត្រូវចុះហត្ថលេខាដោយភាគីទាំងពីរ។

ក្រសួងអាចចាត់ទុកជាមោឃៈ នូវកិច្ចព្រមព្រៀងនេះ ប្រសិនបើការអនុវត្តមុខងាររបស់ រដ្ឋបាលខេត្តមិនសម្រេចតាមគោលដៅ។ ក្រសួងបរិស្ថាន ជូនដំណឹងទៅរដ្ឋបាលខេត្ត មុននឹងចាត់ទុកជាមោឃៈនូវកិច្ចព្រមព្រៀងនេះ។

ធ្វើនៅ២០១៥ឆ្នាំ............ខែ............ថ្ងៃទី..............

| តំណាងក្រសួងបរិស្ថាន | តំណាងរដ្ឋបាលស្រុក |
|---|---|
| អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន | អភិបាលខេត្ត |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសលេខ.............................ចុះថ្ងៃទី..............ខែ..............ឆ្នាំ..............**

**ស្តីពីការផ្ទេរប្រតិភូកម្មមុខងារការគ្រប់គ្រងតំបន់ការពារធម្មជាតិ**

**ដល់រដ្ឋបាលក្រុង ស្រុក ដែលមានតំបន់ការពារធម្មជាតិ**

| ល.រ | រដ្ឋបាលក្រុង ស្រុក | ឈ្មោះតំបន់ការពារធម្មជាតិ | ទំហំ | ថវិកា | ផ្សេងៗ |
|---|---|---|---|---|---|
| 1 | កំពង់ស្ពឺ | | | | |
| | ភ្នំស្រួច | ឧទ្យានជាតិព្រះសុរាម្រិត កុសមៈ គីរីរម្យ<br>ឧទ្យានជាតិព្រះមុនីវង្ស បូកគោ | | | |
| | ឱរ៉ាល់ | ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ | | | |
| | ថ្ពង | ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ | | | |
| 2 | ព្រះសីហនុ | | | | |
| | ព្រៃនប់ | ឧទ្យានជាតិព្រះសីហនុ រាម<br>ឧទ្យានជាតិព្រះមុនីវង្ស បូកគោ | | | |
| | កំពង់សីលា | ឧទ្យានជាតិព្រះកុសមៈ គីរីរម្យ<br>ឧទ្យានជាតិព្រះមុនីវង្ស បូកគោ | | | |
| 3 | កោះកុង | | | | |
| | ក្រុង ខេមរភូមិន្ទ | ដែនជម្រកសត្វព្រៃពាមក្រសោប | | | |
| | បុទុមសាគរ | ឧទ្យានជាតិបុទុមសាគរ<br>តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង | | | |

| | | | | | |
|---|---|---|---|---|---|
| | ស្រែអំបិល | តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង | | | |
| | មណ្ឌលសីមា | ដែនជម្រកសត្វព្រៃពាមក្រសោម<br>ដែនជម្រកសត្វព្រៃភ្នំសំកុសភូមិសាស្ត្រខេត្តកោះកុង | | | |
| | គិរីសាគរ | ឧទ្យានជាតិបុទុមសាគរ | | | |
| | កោះកុង | ឧទ្យានជាតិបុទុមសាគរ<br>ដែនជម្រកសត្វព្រៃពាមក្រសោប | | | |
| 4 | កែប | | | | |
| | ក្រុង កែប | ឧទ្យានជាតិកែប | | | |
| 5 | កំពត | | | | |
| | ទឹកឈូរ | ឧទ្យានជាតិព្រះមុនីវង្ស បូកគោ ភូមិសាស្ត្រខេត្តកំពត | | | |
| | ឈូក | ឧទ្យានជាតិព្រះមុនីវង្ស បូកគោ ភូមិសាស្ត្រខេត្តកំពត | | | |
| | ក្រុងកំពត | ឧទ្យានជាតិព្រះមុនីវង្ស បូកគោ ភូមិសាស្ត្រខេត្តកំពត | | | |
| 6 | ប៉ៃលិន | | | | |
| | ក្រុង ប៉ៃលិន | តំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូតភូមិសាស្ត្រប៉ៃលិន | | | |
| 7 | បាត់ដំបង | | | | |
| | ឯកភ្នំ | តំបន់ស្នូលព្រែកទាល់ | | | |
| | ភ្នំព្រឹក | តំបន់ដែនជម្រកសត្វព្រៃរនាមដូនសំ | | | |
| | សំឡូត | តំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត<br>តំបន់ដែនជម្រកសត្វព្រៃភ្នំសំកុស | | | |
| 8 | សៀមរាប | | | | |

| | | | | | |
|---|---|---|---|---|---|
| | ក្រុង សៀមរាប | ការពារទេសភាពអង្គរ | | | |
| | ជីក្រែង | ដែនជម្រកសត្វព្រៃបឹងពែរ | | | |
| | ពួក | ការពារទេសភាពអង្គរ | | | |
| | បន្ទាយស្រី | ការពារទេសភាពអង្គរ | | | |
| | ស្វាយលើ | តំបន់ដែនជម្រកសត្វព្រៃគូលែន ព្រហ្មទេព | | | |
| | វ៉ារិន | តំបន់ដែនជម្រកសត្វព្រៃគូលែន ព្រហ្មទេព | | | |
| | អង្គរធំ | ការពារទេសភាពអង្គរ | | | |
| | ស្ទោង | ដែនជម្រកសត្វព្រៃបឹងពែរភូមិសាស្ត្រខេត្តកំពង់ធំ<br>តំបន់ស្នូលបឹងទន្លេធ្មារ | | | |
| | កំពង់ស្វាយ | តំបន់ស្នូលស្ទឹងសែន | | | |
| | ប្រាសាទបល្ល័ង្គ | ដែនជម្រកសត្វព្រៃបឹងពែរភូមិសាស្ត្រខេត្តកំពង់ធំ | | | |
| | ប្រាសាទសម្បូរ | ដែនជម្រកសត្វព្រៃបឹងពែរភូមិសាស្ត្រខេត្តកំពង់ធំ | | | |
| | សណ្ដាន់ | ដែនជម្រកសត្វព្រៃបឹងពែរភូមិសាស្ត្រខេត្តកំពង់ធំ | | | |
| 10 | ឧត្តរមានជ័យ | | | | |
| | បន្ទាយអំពិល | តំបន់ការពារទេសភាពបន្ទាយឆ្មារ | | | |
| | អន្លង់វែង | ដែនជម្រកសត្វព្រៃគូលែន ព្រហ្មទេព | | | |
| | ត្រពាំងប្រាសាទ | ដែនជម្រកសត្វព្រៃគូលែន ព្រហ្មទេព | | | |
| 11 | មណ្ឌលគិរី | | | | |
| | ក្រុង សែនមនោរម្យ | ដែនជម្រកសត្វព្រៃភ្នំព្រេច | | | |
| | កែវ សីមា | ដែនជម្រកសត្វព្រៃភ្នំព្រេច | | | |

| | | | | | |
|---|---|---|---|---|---|
| | កោះញែក | ដែនជម្រកសត្វព្រៃភ្នំព្រេច<br>ដែនជម្រកសត្វព្រៃលំផាត់ | | | |
| | អូររាំង | ដែនជម្រកសត្វព្រៃភ្នំណាមលៀរ | | | |
| | ពេជ្រាដា | ដែនជម្រកសត្វព្រៃភ្នំណាមលៀរ | | | |
| 12 | រតនគិរី | | | | |
| | វើនសៃ | ឧទ្យានជាតិវីរៈជ័យ | | | |
| | លំផាត់ | ដែនជម្រកសត្វព្រៃលំផាត់ | | | |
| | កូនមុំ | ដែនជម្រកសត្វព្រៃលំផាត់ | | | |
| | អណ្ដូងមាស | ឧទ្យានជាតិវីរៈជ័យ | | | |
| | តាវែង | ឧទ្យានជាតិវីរៈជ័យ | | | |
| 13 | ស្ទឹងត្រែង | | | | |
| | ក្រុង ស្ទឹងត្រែង | តំបន់រ៉ាមសារទន្លេមេគង្គលើខេត្តស្ទឹងត្រែង | | | |
| | ថាឡាបរីវ៉ាត់ | តំបន់រ៉ាមសារទន្លេមេគង្គលើខេត្តស្ទឹងត្រែង | | | |
| | សៀមប៉ាង | ឧទ្យានជាតិវីរៈជ័យខេត្តស្ទឹងត្រែង | | | |
| 14 | ព្រះវិហារ | | | | |
| | ក្រុង ព្រះវិហារ | ដែនជម្រកសត្វព្រៃគូលែន ព្រហ្មទេព | | | |
| | រវៀង | ដែនជម្រកសត្វព្រៃបឹងពែរ | | | |
| | ជាំក្សាន្ត | ដែនជម្រកសត្វព្រៃគូលែន ព្រហ្មទេព<br>តំបន់ការពារទេសភាពប្រាសាទព្រះវិហារ | | | |
| | គូលែន | ដែនជម្រកសត្វព្រៃគូលែន ព្រហ្មទេព | | | |

| | | | | | |
|---|---|---|---|---|---|
| | សង្គមថ្មី | ដែនជម្រកសត្វព្រៃបឹងពែរ | | | |
| | ត្បែងមានជ័យ | ដែនជម្រកសត្វព្រៃគូលែន ព្រហ្មទេព | | | |
| 15 | បន្ទាយមានជ័យ | | | | |
| | ថ្មពួក | តំបន់ការពារទេសភាពបន្ទាយឆ្មារ | | | |
| | ម៉ាឡៃ | ដែនជម្រកសត្វព្រៃនាមដូនសំ ស្រុកម៉ាឡៃ | | | |
| 16 | កំពង់ឆ្នាំង | | | | |
| | កំពង់លែង | តំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងទន្លេសាប | | | |
| | បរិបូណ៌ | តំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងទន្លេសាប | | | |
| | ទឹកផុស | ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ | | | |
| 17 | ក្រចេះ | | | | |
| | ស្នួល | ដែនជម្រកសត្វព្រៃស្នួល | | | |
| 18 | ពោធិ៍សាត់ | | | | |
| | បាកាន | តំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងទន្លេសាប | | | |
| | ក្រគរ | តំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងទន្លេសាប<br>ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ | | | |
| | ភ្នំក្រវាញ | ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ | | | |
| | កណ្ដៀង | តំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងទន្លេសាប | | | |
| | វាលវែង | ដែនជម្រកសត្វព្រៃភ្នំសំកុស | | | |
| សរុប | | | | 64 | |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ................................ចុះថ្ងៃទី...............ខែ...............ឆ្នាំ...............**

**ស្តីពីការធ្វើប្រតិភូកម្មមុខងារការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ**

| ល.រ | រដ្ឋបាលថ្នាក់ក្រោមជាតិ | | | ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ | ផ្សេងៗ |
|---|---|---|---|---|---|
| | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ | | |
| 1 | កំពង់ស្ពឺ | | | | |
| | | ភ្នំស្រួច | ចំបក់ | សហគមន៍តំបន់ការពារធម្មជាតិចំបក់ | |
| | | ឱរ៉ាល់ | តាសាល | សហគមន៍តំបន់ការពារធម្មជាតិចំបតាសាល | |
| | | | ត្រពាំងជោ | សហគមន៍តំបន់ការពារធម្មជាតិកោដូនតី<br>សហគមន៍តំបន់ការពារធម្មជាតិ ត្រាចំបក់ | |
| | | ថ្ពង | អមលាំង | សហគមន៍តំបន់ការពារធម្មជាតិដងផ្ទំរមៀត<br>សហគមន៍តំបន់ការពារធម្មជាតិគោកមានទី | |
| 2 | ព្រះសីហនុ | | | | |
| | | ព្រៃនប់ | អូជ្រៅ និងបឹងតាព្រហ្ម | សហគមន៍ព្រៃឈើនិងនេសាទក្នុងឧទ្យានជាតិព្រះសីហនុ"រាម" | |

| | | | | | |
|---|---|---|---|---|---|
| 3 | កោះកុង | | | | |
| | | ក្រុង ខេមរភូមិន្ទ | សង្កាត់ ស្ទឹងវែង | សហគមន៍តំបន់ការពារធម្មជាតិស្ទឹងវែង | |
| | | បទុមសាគរ | អណ្តូងទឹក | សហគមន៍តំបន់ការពារធម្ម ជាតិអណ្តូងទឹក<br>សហគមន៍តំបន់ការពារធម្មជាតិទឹកធ្លាក់ឆាយ១២ជាន់ | |
| | | | កណ្តាល | សហគមន៍តំបន់ការពារធម្មជាតិកណ្តោយ | |
| | | ស្រែអំបិល | ជ្រួយស្វាយ | សហគមន៍តំបន់ការពារធម្មជាតិជ្រោយស្វាយ | |
| | | | ស្រែអំបិល ដងពែង | សហគមន៍តំបន់ការពារធម្មជាតិត្រពាំង-ចំការក្រោម | |
| | | | ជីខលើ | សហគមន៍តំបន់ការពារធម្មជាតិជីខលើ | |
| | | | ជីខក្រោម | សហគមន៍តំបន់ការពារធម្មជាតិជីខក្រោម | |
| | | មណ្ឌលសីមា | ពាមក្រសោប | សហគមន៍តំបន់ការពារធម្មជាតិពាមក្រសោប | |
| | | | ទួលគគីរ | សហគមន៍តំបន់ការពារធម្មជាតិទទួលគគីរ | |
| | | | បាក់ក្លង | សហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង | |
| | | កោះកុង | កោះកាពិ | សហគមន៍តំបន់ការពារធម្មជាតិកោះកាពិ<br>សហគមន៍តំបន់ការពារធម្មជាតិកោះស្រឡៅ | |
| 4 | កំពត | | | | |
| | | ទឹកឈូរ | ព្រែកត្នោត | សហគមន៍តំបន់ការពារធម្មជាតិព្រែកត្នោត | |
| | | ក្រុងកំពត | អណ្តូងខ្មែរ | សហគមន៍តំបន់ការពារធម្មជាតិអូរតូច | |

| | | | | | |
|---|---|---|---|---|---|
| 5 | ប៉ៃលិន | | | | |
| | | ក្រុង ប៉ៃលិន | បយ៉ាខា | សហគមន៍តំបន់ការពារធម្មជាតិទឹកជ្រោះបយ៉ាខាភូមិហ៊ុយត្បូង | |
| 6 | បាត់ដំបង | | | | |
| | | ឯកភ្នំ | កោះជីវាំង | សហគមន៍ទូកដឹកជញ្ជូនភ្ញៀវទេសចរណ៍ | |
| | | សំឡូត | តាតោក | សហគមន៍តំបន់ការពារធម្មជាតិតាតោក អូរក្រូច<br>សហគមន៍តំបន់ការពារធម្មជាតិភ្នំទឹកធ្លាក់<br>សហគមន៍តំបន់ការពារធម្មជាតិអូរត្រែង<br>សហគមន៍តំបន់ការពារធម្មជាតិពាមតា | |
| | | | កំពង់ល្ពៅ | សហគមន៍តំបន់ការពារធម្មជាតិអូរដាំ | |
| 7 | សៀមរាប | | | | |
| | | ជីក្រែង | ពង្រក្រោម | ដំណាក់ខ្នាចគ្រាច | |
| | | | ពង្រលើ | ព្រៃធំ | |
| | | | ខ្វាវ | ភ្នំបាល័ង្គ | |
| | | ស្វាយលើ | កន្ទួត | ជប់សោម | |
| | | វ៉ារិន | តាសៀម | ក្រមុំបួល | |
| 8 | កំពង់ធំ | | | | |
| | | ស្ទោង | ពពក | សហគមន៍តំបន់ការពារធម្មជាតិ អន្លង់ក្រាញ់ | |
| | | | ពាមបាង | សហគមន៍តំបន់ការពារធម្មជាតិ បាឡត | |

| | | | | | |
|---|---|---|---|---|---|
| | | កំពង់ស្វាយ | ផាត់សន្ដាយ | ទួលនាងសាវផ្លូវហ្លួង | |
| | | ប្រាសាទបល្ល័ង្គ | សាគ្រាម | សហគមន៍តំបន់ការពារធម្មជាតិអូរបញ្ញា<br>សហគមន៍តំបន់ការពារធម្មជាតិអូរជញ្ជៀន<br>សហគមន៍តំបន់ការពារធម្មជាតិ ត្រពាំងក្រោលគោ<br>សហគមន៍តំបន់ការពារធម្មជាតិ អូរប្រសាទ<br>សហគមន៍តំបន់ការពារធម្មជាតិ ភ្នំប្រង់ | |
| | | | សាលាវិស័យ | សហគមន៍តំបន់ការពារធម្មជាតិជាំម្រេច | |
| | | ប្រាសាទសម្បូរ | សម្បូរ | សហគមន៍តំបន់ការពារធម្មជាតិ បឹងទទឹង | |
| | | សណ្ដាន់ | មានជ័យ | សហគមន៍តំបន់ការពារធម្មជាតិ ត្រពាំងប្រិយធំ | |
| | | | ងន | សហគមន៍តំបន់ការពារធម្មជាតិ ជាំធ្លក<br>សហគមន៍តំបន់ការពារធម្មជាតិ ក្បិតចង្កូរខ្លា | |
| | | | សណ្ដាន់ | សហគមន៍តំបន់ការពារធម្មជាតិ ស្គរក្រូច | |
| | | | ដងកាំបិត | សហគមន៍តំបន់ការពារធម្មជាតិ គគីរប្រហោង | |
| 9 | ឧត្ដរមានជ័យ | | | | |
| | | ត្រពាំងប្រាសាទ | ត្រពាំងប្រាសាទ | រំដួលព្រៃស្រស់ សម្រស់ភ្នំពល់ | |
| | | | ប្រឡាយ | រំដួលព្រៃស្រស់ សម្រស់ត្រាំប៉ោង | |
| 10 | មណ្ឌលគិរី | | | | |

| | | | | | |
|---|---|---|---|---|---|
| | | ក្រុង សែនមនោរម្យ | រមនា | ស្រែអ៊ី ណុាំកុំ | |
| | | កែវ សីមា | ចុងផ្លាស់ | សហគមន៍តំបន់ការពារធម្មជាតិពូទុង ពូហ៊ិងណាំហាំង<br>សហគមន៍តំបន់ការពារធម្មជាតិរនុស ខ្វែង | |
| | | កោះញែក | សុខសាន្ត | សហគមន៍តំបន់ការពារធម្មជាតិជ្ជូក្លប់ ជួងក្ដីសង្ឃឹម<br>សហគមន៍តំបន់ការពារធម្មជាតិស្រែធំ ម្នឹង | |
| 11 | រតនគិរី | | | | |
| | | វើនសៃ | កុកឡាក់ | សហគមន៍តំបន់ការពារធម្មជាតិ អូរទុង | |
| | | លំផាត់ | សេដា | សហគមន៍តំបន់ការពារធម្មជាតិ ភូមិថ្មី | |
| | | | ជ័យឧត្ដម | សហគមន៍តំបន់ការពារធម្មជាតិ វាលកំបោរ | |
| | | កូនមុំ | សេរីមង្គល | សហគមន៍តំបន់ការពារធម្មជាតិ អូររ៉ៃ | |
| | | | ស្រែអង្គ្រង | សហគមន៍តំបន់ការពារធម្មជាតិ អូរគគី | |
| | | តាវែង | តាវែងលើ | សហគមន៍តំបន់ការពារធម្មជាតិ អូរតាបូក<br>សហគមន៍តំបន់ការពារធម្មជាតិ មណ្ឌលយ៉ន | |
| | | | តាវែងក្រោម | សហគមន៍តំបន់ការពារធម្មជាតិ អូរខាំផា | |
| 12 | ស្ទឹងត្រែង | | | | |

| | | | | | |
|---|---|---|---|---|---|
| | | ក្រុង ស្ទឹងត្រែង | សង្កាត់សាមគ្គី | សហគមន៍នេសាទ អន្លង់ថ្មបាំង ភូមិខេ<br>សហគមន៍នេសាទភូមិខាំផាន់<br>សហគមន៍នេសាទ អន្លង់កោះកាង ភូមិកោះខនឌិន<br>សហគមន៍នេសាទ ភូមិថ្មី | |
| | | ថាឡាបរិវ៉ាត់ | ព្រះរំកិល | សហគមន៍នេសាទភូមិកោះឈើទាលធំ<br>សហគមន៍នេសាទភូមិកោះល្វ<br>សហគមន៍នេសាទអន្លងមាស ភូមិកោះឈើទាលតូច<br>សហគមន៍នេសាទភូមិក្រឡាពាល | |
| | | | អូរស្វាយ | សហគមន៍នេសាទភូមិកោះញ្ញៅ<br>សហគមន៍នេសាទភូមិអូរស្វាយ<br>សហគមន៍នេសាទអូររុន<br>សហគមន៍នេសាទភូមិរនៃសៀន<br>សហគមន៍នេសាទភូមិកោះហឹប | |
| | | | កោះស្នែង | សហគមន៍នេសាទអន្លង់កោះកន្ទាយ ភូមិដាំធំ<br>សហគមន៍នេសាទកអន្លង់កោះកី ភូមិកោះកី<br>សហគមន៍នេសាទភូមិកោះស្នែង<br>សហគមន៍នេសាទភូមិកោះស្រឡៅ | |
| | | សៀមប៉ាង | សន្តិភាព | សហគមន៍តំបន់ការពារធម្មជាតិ អូរចាយ | |
| | | | ថ្មកែវ | សហគមន៍តំបន់ការពារធម្មជាតិ អូរចាយ | |

| | | | | | |
|---|---|---|---|---|---|
| 13 | ព្រះវិហារ | | | | |
| | | រវៀង | រមនីយ | សហគមន៍តំបន់ការពារធម្មជាតិជីអោកបឹងប្រិយ<br>សហគមន៍តំបន់ការពារធម្មជាតិជាំប្រិយ<br>សហគមន៍តំបន់ការពារធម្មជាតិភ្នំព្រះលាន<br>សហគមន៍តំបន់ការពារធម្មជាតិបឹងទន្លេម្រេច | |
| | | | រុងរឿង | ជ្រាប់ពួយរុងរឿង | |
| | | ជាំក្សាន្ត | យាង | សហគមន៍តំបន់ការពារធម្មជាតិជាំតាមឿន<br>សហគមន៍តំបន់ការពារធម្មជាតិរលំទឹកខ្មៅទឹកស<br>សហគមន៍តំបន់ការពារធម្មជាតិទំនប់អូរតាក្អែក | |
| | | | ព្រីងធំ | សហគមន៍តំបន់ការពារធម្មជាតិព្រៃថ្មគោល | |
| | | គូលែន | ស្រយ៉ង់ | សហគមន៍តំបន់ការពារធម្មជាតិសំបូរអភិវឌ្ឍន៍<br>សហគមន៍តំបន់ការពារធម្មជាតិអភិវឌ្ឍន៍ព្រៃវែង | |
| | | សង្គមថ្មី | រណសិរ្ស | សហគមន៍តំបន់ការពារធម្មជាតិស្ទឹងក្រសាំង<br>សហគមន៍តំបន់ការពារធម្មជាតិអូរពោន<br>សហគមន៍តំបន់ការពារធម្មជាតិអូរស្រស់<br>សហគមន៍តំបន់ការពារធម្មជាតិអូរសុភាព | |
| 14 | បន្ទាយមានជ័យ | | | | |

| | | | | | |
|---|---|---|---|---|---|
| | | ថ្មពួក | បន្ទាយឆ្មារ | សហគមន៍ភូមិត្រពាំងធ្លក<br>សហកមន៍ភូមិដងរ៉េក | |
| | | | គំរូ | សហគមន៍ភូមិតាយើង | |
| | | | គោករមៀត | សហគមន៍ភូមិថ្មី<br>សហគមន៍ភូមិបឹងតាស្រី<br>សហគមន៍ភូមិតាម៉ុង | |
| | | ម៉ាឡៃ | ទួលពង្រ | សហគមន៍ភូមិអូរអំពិល<br>សហគមន៍ភូមិបន្ទាយទី១<br>សហគមន៍ភូមិទួលពង្រ<br>សហគមន៍ភូមិខ្លាងាប់<br>សហគមន៍ភូមិកោះស្នួល | |
| 15 | កំពង់ឆ្នាំង | | | | |
| | | កំពង់លែង | ផ្លូវទូក | សហគមន៍នេសាទ ថ្នល់ឈើទាល<br>សហគមន៍នេសាទស្លូតពាមខ្នង | |
| | | | ប្រឡាយមាស | សហគមន៍នេសាទ ក្រម៉ាល់ | |

| | | | | | |
|---|---|---|---|---|---|
| | | ទឹកផុស | ក្បាលទឹក | សហគមន៍តំបន់ការពារធម្មជាតិ អន្លង់ស្វាយ<br>សហគមន៍តំបន់ការពារធម្មជាតិព្រៃធំអន្លងថ្ម<br>សហគមន៍តំបន់ការពារធម្មជាតិ ម៉ាម្លង់<br>សហគមន៍តំបន់ការពារធម្មជាតិ ខ្នងរមាត | |
| | | | ទួលខ្ពស់ | សហគមន៍តំបន់ការពារធម្មជាតិ ភូមិស្លែង | |
| | | | ជៀក | សហគមន៍តំបន់ការពារធម្មជាតិ ភ្នំជើងលៀង | |
| 16 | ក្រចេះ | | | | |
| | | ស្នួល | ឃ្សឹម | សហគមន៍តំបន់ការពារធម្មជាតិ៣ ភូមិ ដូង មិល ឃ្សឹមក្នុង | |
| 17 | ពោធិ៍សាត់ | | | | |
| | | ក្រគរ | ឈើតុំ | សហគមន៍តំបន់ការពារធម្មជាតិទឹកធ្លាក់ច្រកល្បៀង | |
| | | | អន្សាចំបក់ | សហគមន៍តំបន់ការពារធម្មជាតិ កោះទន្លាក្រាស់ | |
| | | ភ្នំក្រវាញ | សន្ត្រែ | សហគមន៍តំបន់ការពារធម្មជាតិ រាំងខ្វារ | |
| | | វាលវែង | អន្លង់រាប | សហគមន៍តំបន់ការពារធម្មជាតិចំការជ្រៃខាងជើង<br>សហគមន៍តំបន់ការពារធម្មជាតិក្រាំងរងៀង<br>សហគមន៍តំបន់ការពារធម្មជាតិចំការជ្រៃត្បូង<br>សហគមន៍តំបន់ការពារធម្មជាតិ ភូមិកណ្តាល<br>សហគមន៍តំបន់ការពារធម្មជាតិ ដីក្រហម | |

| | | | | | |
|---|---|---|---|---|---|
| | | | ប្រម៉ោយ | សហគមន៍តំបន់ការពារធម្មជាតិស្ទឹងថ្មី<br>សហគមន៍តំបន់ការពារធម្មជាតិ ស្រែពាំង<br>សហគមន៍តំបន់ការពារធម្មជាតិភូមិផ្ទិកជ្រុំ,ឈើទាលជ្រុំ<br>សហគមន៍តំបន់ការពារធម្មជាតិភូមិទំព័រ<br>សហគមន៍តំបន់ការពារធម្មជាតិប្រម៉ោយ | |
| សរុប | | | | 76 ឃុំ | |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ................................ចុះថ្ងៃទី................ខែ................ឆ្នាំ...............

ស្តីពីការធ្វើប្រតិភូកម្មមុខងារការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ

| ល.រ | រដ្ឋបាលស្រុក | ថវិកា | ផ្សេងៗ |
|---|---|---|---|
| 1 | កំពង់ស្ពឺ | | |
| | បសេដ្ឋ | | |
| | គងពិសី | | |
| | ឧត្តុង្គ | | |
| | សំរោងទង | | |
| | ភ្នំស្រួច | | |
| | ឱរ៉ាល់ | | |
| | ថ្ពង | | |
| 2 | ព្រះសីហនុ | | |
| | ព្រៃនប់ | | |
| | កំពង់សីលា | | |
| | ស្ទឹងហាវ | | |
| 3 | កោះកុង | | |
| | បុទុមសាគរ | | |

| | | | |
|---|---|---|---|
| | ស្រែអំបិល | | |
| | មណ្ឌលសីមា | | |
| | គិរីសាគរ | | |
| | កោះកុង | | |
| | ថ្មបាំង | | |
| 4 | កែប | | |
| | ដំណាក់ចង្អើរ | | |
| 5 | កំពត | | |
| | ទឹកឈូរ | | |
| | កំពង់ត្រាច | | |
| | ឈូក | | |
| | បន្ទាយមាស | | |
| | អង្គរជ័យ | | |
| | ដងទង់ | | |
| | ជុំគិរី | | |
| | ក្រុងកំពត | | |
| 6 | ប៉ៃលិន | | |
| | ក្រុង ប៉ៃលិន | | |
| | សាលាក្រៅ | | |
| 7 | បាត់ដំបង | | |
| | ថ្មគោល | | |

| | | | |
|---|---|---|---|
| | មោងឫស្សី | | |
| | សង្កែ | | |
| | បាណន់ | | |
| | បវេល | | |
| | ឯកភ្នំ | | |
| | ភ្នំព្រឹក | | |
| | កំរៀង | | |
| | រតនមណ្ឌល | | |
| | សំឡូត | | |
| | គាស់ក្រឡ | | |
| | រុក្ខគិរី | | |
| | សំពៅលូន | | |
| 8 | សៀមរាប | | |
| | ជីក្រែង | | |
| | ពួក | | |
| | សូទ្រនិគម | | |
| | ប្រាសាទបាគង | | |
| | ក្រឡាញ់ | | |
| | អង្គរជុំ | | |
| | បន្ទាយស្រី | | |
| | ស្រីស្នំ | | |

| | | | |
|---|---|---|---|
| | ស្វាយលើ | | |
| | វ៉ារិន | | |
| | អង្គរធំ | | |
| 9 | កំពង់ធំ | | |
| | បារាយណ៍ | | |
| | ស្ទោង | | |
| | កំពង់ស្វាយ | | |
| | សន្ទុក | | |
| | ប្រាសាទបល្ល័ង្គ | | |
| | ប្រាសាទសម្បូរ | | |
| | សណ្ដាន់ | | |
| 10 | ឧត្តរមានជ័យ | | |
| | ក្រុង សំរោង | | |
| | បន្ទាយអំពិល | | |
| | អន្លង់វែង | | |
| | ត្រពាំងប្រាសាទ | | |
| | ចុងកាល់ | | |
| 11 | មណ្ឌលគិរី | | |
| | កែវ សីមា | | |
| | កោះញែក | | |
| | អូររាំង | | |

| | | | |
|---|---|---|---|
| | ពេជ្រាដា | | |
| 12 | រតនគិរី | | |
| | អូជុំ | | |
| | វើនសៃ | | |
| | បរកែវ | | |
| | លំផាត់ | | |
| | កូនមុំ | | |
| | អណ្ដូងមាស | | |
| | អូរយ៉ាដាវ | | |
| | តាវែង | | |
| 13 | ស្ទឹងត្រែង | | |
| | ថាឡាបរិវ៉ាត់ | | |
| | សៀមប៉ាង | | |
| | សេសាន | | |
| | សៀមបូក | | |
| 14 | ព្រះវិហារ | | |
| | រវៀង | | |
| | ជាំក្សាន្ត | | |
| | គូលែន | | |
| | ជ័យសែន | | |
| | សង្គមថ្មី | | |

| | | | |
|---|---|---|---|
| | ឆែប | | |
| | ត្បែងមានជ័យ | | |
| 15 | បន្ទាយមានជ័យ | | |
| | សិរីសោភ័ណ្ឌ | | |
| | មង្គលបូរី | | |
| | ព្រះនេត្រព្រះ | | |
| | អូរជៅ | | |
| | ភ្នំស្រុក | | |
| | ស្វាយចេក | | |
| | ប៉ោយប៉ែត | | |
| | ថ្មពួក | | |
| | ម៉ាឡៃ | | |
| 16 | កំពង់ឆ្នាំង | | |
| | ក្រុងកំពង់ឆ្នាំង | | |
| | រលាប្អៀរ | | |
| | កំពង់ត្រឡាច | | |
| | សាមគ្គីមានជ័យ | | |
| | កំពង់លែង | | |
| | បរិបូណ៌ | | |
| | ទឹកផុស | | |
| | ជលគិរី | | |

| | | | |
|---|---|---|---|
| 17 | ក្រចេះ | | |
| | ព្រែកប្រសព្វ | | |
| | ឆ្លូង | | |
| | សម្បូរ | | |
| | ស្នួល | | |
| | ចិត្របូរី | | |
| 18 | ពោធិ៍សាត់ | | |
| | បាកាន | | |
| | ក្រគរ | | |
| | ភ្នំក្រវាញ | | |
| | កណ្តៀង | | |
| | វាលវែង | | |
| 19 | ព្រៃវែង | | |
| | ពារាំង | | |
| | ព្រះស្តេច | | |
| | កំពង់ត្របែក | | |
| | ស្វាយអន្ទរ | | |
| | មេសាង | | |
| | បាភ្នំ | | |
| | ស៊ីធរកណ្តាល | | |
| | កញ្ជ្រៀច | | |

| | | | |
|---|---|---|---|
| | ពាមជរ | | |
| | កំចាយមារ | | |
| | ពាមរក៍ | | |
| | កំពង់លាវ | | |
| 20 | ស្វាយរៀង | | |
| | រមាសហែក | | |
| | ស្វាយជ្រំ | | |
| | កំពង់រោទិ៍ | | |
| | រំដួល | | |
| | ស្វាយទាប | | |
| | ចន្ទ្រា | | |
| 21 | តាកែវ | | |
| | បាទី | | |
| | ត្រាំកក់ | | |
| | សំរោង | | |
| | ទ្រាំង | | |
| | គិរីវង់ | | |
| | ព្រៃកប្បាស | | |
| | អង្គរបូរី | | |
| | កោះអណ្ដែត | | |
| | បុរីជលសារ | | |

| | | | |
|---|---|---|---|
| 22 | កណ្ដាល | | |
| | កៀនស្វាយ | | |
| | ស្អាង | | |
| | កោះធំ | | |
| | ខ្សាច់កណ្ដាល | | |
| | ពញាឮ | | |
| | មុខកំពូល | | |
| | អង្គស្នួល | | |
| | កណ្ដាលស្ទឹង | | |
| | ល្វាឯម | | |
| | លើកដែក | | |
| 23 | កំពង់ចាម | | |
| | ព្រៃឈរ | | |
| | ចម្ការលើ | | |
| | ស្រីសន្ធរ | | |
| | ស្ទឹងត្រង់ | | |
| | កំពង់សៀម | | |
| | បាធាយ | | |
| | កងមាស | | |
| | ជើងព្រៃ | | |
| | កោះសូទិន | | |

| | | | |
|---|---|---|---|
| 24 | ត្បូងឃ្មុំ | | |
| | មេមត់ | | |
| | ពញាក្រែក | | |
| | ក្រូចឆ្មា | | |
| | កំបែរ | | |
| | អូររាំងឪ | | |
| 25 | រាជធានីភ្នំពេញ | | |
| | ដង្កោ | | |
| | មានជ័យ | | |
| | ចម្ការមន | | |
| | ទួលគោក | | |
| | ឫស្សីកែវ | | |
| | ដូនពេញ | | |
| | ៧មករា | | |
| | សែនសុខ | | |
| | ពោធិសែនជ័យ | | |
| សរុប | | 173 ស្រុក | |

VI.**សំណូមពរ**

-រដ្ឋបាលថ្នាក់ក្រោមជាតិស្នើឱ្យក្រសួងបរិស្ថាននៅបន្តការគាំទ្របច្ចេកទេសពីឧទ្យាននុរក្ស និងអ្នកពាក់ព័ន្ធក្នុងការអនុវត្តមុខងារនេះ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម** មេត្តាជ្រាបជារបាយការណ៍។
សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។